# ACRA's Newsletter

# January, 2018

## ប្រធានបទៈ កិច្ចប្រជុំស្តីពី "ការធ្វើបច្ចុប្បន្នភាពនៃនីតិវិធីធ្វើលិខិតធ្វើដំណើរពលករទៅធ្វើការនៅព្រះរាជាណាចក្រថៃឡង់ដ៍"

ថ្ងៃទី០១ រោច ខែ បុស្ស ឆ្នាំ រកា ព.ស ២៥៦១ ត្រូវនឹង ថ្ងៃ០២ មករា ឆ្នាំ២០១៨ នៅសាលប្រជុំរបស់សមាគម អាក្រា សមាគមអាក្រាបានរៀបចំកិច្ចប្រជុំមួយ ជាមួយសមាជិករបស់ខ្លួន ស្តីពី "ការធ្វើបច្ចុប្បន្នភាពនៃនីតិវិធីធ្វើលិខិតធ្វើដំណើរពលករទៅធ្វើការ នៅព្រះរាជាណាចក្រថៃឡង់ដ៍" ។



លោកជំទាវឧកញ៉ា **អ៊ឹង ស៊ាងរិទ្ធី** ប្រធានសមាគមអាក្រា បានមានប្រសាសន៍ថា ទាក់ទិននឹងការធ្វើលិខិតធ្វើដំណើរពលករ ថា នៅថ្ងៃទី ០៥ មករា ឆ្នាំ២០១៨ ក្រសួងមហាផ្ទៃនឹងសម្ភោធដាក់ អោយធ្វើលិខិតធ្វើដំណើរពលករនៅភ្នំពេញ (ផ្សារទំនើបស្ទឹងមានជ័យជាន់ទី២) តំបន់ប៉ោយប៉ែត (ច្រកចេញចូលតែមួយ) និង តំបន់បាត់ដំបង (ច្រកចេញចូលតែមួយ) ។ នៅក្នុងប្រព័ន្ធOCWC បានកំណត់ច្បាស់ពី ហ្បូន ដែលត្រូវថត ដូចជា តំបន់ប៉ោយប៉ែត តំបន់បាត់ដំបង និង ភ្នំពេញ ប៉ុន្តែការបង់ប្រាក់ធ្វើ លិខិតធ្វើដំណើរ ជាសមាគមគឺនៅភ្នំពេញ។







## ប្រធានបទៈ "ដំណើរទស្សនៈកិច្ច វិទ្យាស្ថាននៃបច្ចេកវិទ្យាជប៉ុន(JQC)"

នៅព្រឹកថ្ងៃ០៩ រោច ខែបុស្ស ឆ្នាំរកា ព.ស ២៥៦១ ត្រូវនឹងថ្ងៃពុធ ទី១០ ខែមករា ឆ្នាំ២០១៨ លោកជំទាវឧកញ៉ា **អ៊ឹង ស៊ាងរិទ្ធី** ប្រធានសមាគមអាក្រា លោក **ពិន ទិរៈ** នាយកប្រតិបត្តិសមាគមអាក្រា បានចូលរួមជាមួយនឹងគណៈប្រតិភូជប៉ុន និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានធ្វើដំណើរទស្សនៈកិច្ច វិទ្យាស្ថាននៃបច្ចេកវិទ្យាជប៉ុន(JQC) ដៃគូសហការជាមួយក្រុមហ៊ុន PRO-CAST (CAMBODIA) ដែលជាសមាជិកសមាគមអាក្រា ។







**<u>ប្រធានបទ៖ កិច្ចប្រជុំស្តីពី "វគ្គបណ្តុះបណ្តាល ស្តីពី នីតិវិធីនៃការរៀបចំធ្វើលិខិតធ្វើដំណើរពលករខ្មែរទៅធ្វើការនៅព្រះរាជាណាចក្រថៃឡង់ដ៍"</u>**

នៅរសៀលថ្ងៃ ៩រោច ខែបុស្ស ឆ្នាំរកា ព.ស ២៥៦១ ត្រូវនឹងថ្ងៃ ទី ១០ ខែ មករា ឆ្នាំ២០១៧ នៅសាលប្រជុំរបស់សមាគមអាក្រា សមាគមអាក្រាបានរៀបចំកិច្ចប្រជុំមួយ ជាមួយសមាជិករបស់ខ្លួន ស្តីពី "វគ្គបណ្តុះបណ្តាល ស្តីពី នីតិវិធីនៃការរៀបចំធ្វើលិខិតធ្វើដំណើរពលករខ្មែរទៅធ្វើការនៅព្រះរាជាណាចក្រថៃឡង់ដ៍" ក្នុងគោលបំណងផ្តល់នូវចំណេះដឹងថ្មីៗនៃប្រព័ន្ធ OCWC ដល់សមាជិក ។






**<u>ប្រធានបទ៖ កិច្ចប្រជុំស្តីពី "ការរៀបចំផែនការការងារប្រចាំឆ្នាំរបស់កម្មវិធីត្រីកោណក្នុងតំបន់អាស៊ានសម្រាប់ឆ្នាំ២០១៨ និងការត្រួតពិនិត្យអំពីវឌ្ឍនភាព"</u>**

នៅថ្ងៃ ២កើត ខែមាឃ ឆ្នាំរកា ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី ១៨ ខែមករា ឆ្នាំ២០១៨ នៅសណ្ឋាគារ ភ្នំពេញ លោក **ពិន វិរៈ** នាយកប្រតិបត្តិសមាគមអាក្រា និង លោក **ជាញ់ អេងភក្កដា** ទីប្រឹក្សាសមាគមអាក្រា បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មការប្រឹក្សាគម្រោង ស្តីពី "ការរៀបចំផែនការការងារប្រចាំឆ្នាំរបស់កម្មវិធីត្រីកោណក្នុងតំបន់





អាស៊ានសម្រាប់ឆ្នាំ ២០១៨ និង ការត្រួតពិនិត្យអំពីវឌ្ឍនភាព"។

## ប្រធានបទ៖ ពិធីសំណេះសំណាល និង សួរសុខពលករកម្ពុជាដែលកំពុងធ្វើការនៅព្រះរាជាណាចក្រថៃឡង់ដ៍

ថ្ងៃពុធ ៨កើត ខែមាឃ ឆ្នាំរកា ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨ នៅប្រទេសថៃ សមាគមអាក្រា បានចូលរួមពិធីសំណេះសំណាល និងសួរសុខទុក្ខពលករខ្មែរដែលកំពុងធ្វើការនៅក្នុងប្រទេសថៃ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងបានសំណេះសំណាលពលករខ្មែរចំនួន ៥០០ នាក់ដែលកំពុងធ្វើការនៅរោងចក្រ SUN FOOD INTERNATIONAL ខេត្តសារ៉ាក់បុរី ប្រទេសថៃ ដែលបានបញ្ជូនដោយក្រុមហ៊ុន ១៦៨ Manpower ដែលជាសមាជិកសមាគមអាក្រា។















# ACRA's Board Profile



Name : Ung Seangrithy

ACRA's Position : President

Company's Position : President of UNG RITHY GROUP CO., LTD



Name : Nhek Sothear

ACRA's Position : Vice-President

Company's Position : President of SKMM INVESTMENT GROUP CO., LTD



Name : Ken Sorphornrith

ACRA's Position : General Secretary

Company's Position : Vice-President of SOK CHAMNOL CO., LTD



Name : Lim Vouchna

ACRA's Position : General Treasurer

Company's Position : President of C D M TRADING MANPOWER CO., LTD



Name : Seng Settychey

ACRA's Position : Auditor

Company's Position : President of AP TSE &C CAMBODIA RESOURCE CO.,LTD

# ACRA's Secretariat Profile



Name : Pin Vireak
Position : Executive Director



Name : Danh Engkakada
Position : Advisor



Name : Sen Pisethdanyta
Position : Advisor



Name : Sin Kaomeng
Position : Legal Support/Admin



Name : Ken Panha
Position : Administrative Assistant